| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវតម្លើង |
|---|---|---|---|
| ១ | លោក ស៊ិន សេដ្ឋា | ពីអនុមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ២ | លោកស្រី ខុន នារី | ពីអនុមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៣ | លោក អាំង លាងអ៊ី | ពីអនុមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៤ | លោក កែវ អ៊ូលី | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៥ | លោក ឡាយ នាន | ពីអនុមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មីនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្ដម
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់អង្គភាពប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ត្រូវបានតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិល ចំនួន ២៤ រូប របស់ក្រសួង ចំនួន ០៩ ពីឋានន្តរស័ក្តិអនុមន្ត្រី ទៅឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងពីឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តម ទៅឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវតម្លើង |
|---|---|---|---|
| | **អង្គភាពប្រឆាំងអំពើពុករលួយ** | | |
| ១ | លោក **ខួយ លឹមហុង** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ២ | លោក **អ៊ូ វិសាល** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៣ | លោក **សំរិទ្ធ សុវណ្ណារ៉ា** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៤ | លោក **គុយ ឆាយ** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៥ | លោក **ឈឹន កុសល** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៦ | លោកស្រី **ម៉ា សូឃិនដា** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៧ | លោក **អ៊ុក សំណាង** | ពីអនុមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| | **ក្រសួងព័ត៌មាន** | | |
| ៨ | លោក **ខួន សុវណ្ណារិទ្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៩ | លោក **ឆុង រាសី** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ១០ | លោក **ជា ច័ន្ទបរិបូរណ៍** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ១១ | លោក **ខៀវ អាទិត្យា** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| | **ក្រសួងអប់រំ យុវជន និងកីឡា** | | |
| ១២ | លោក **គង់ តូមីកា** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ១៣ | លោកស្រី **ឆាយគីម សុធ្ធាវី** | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ១៤ | ឯកឧត្តម **មុំ ម៉ិនថន** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | |
| ១៥ | លោក **សៀង ធីរិទ្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ១៦ | លោក **អៀង ស៊ីនលី** | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |

| | | | |
|---|---|---|---|
| | **ក្រសួងធម្មការ និងសាសនា** | | |
| ១៧ | លោក **សាយ អំណាន** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ១៨ | លោក **សាន សម្ផស្ស** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| | **ក្រសួងអភិវឌ្ឍន៍ជនបទ** | | |
| ១៩ | លោក **ភាគ សុធា** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| | **ក្រសួងកិច្ចការនារី** | | |
| ២០ | លោកស្រី **សាខឿន សាវ៉ាតឌី** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| | **ក្រសួងពាណិជ្ជកម្ម** | | |
| ២១ | លោកស្រី **គង់ សិទ្ធិកា** | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ២២ | លោក **ផាន អួន** | ពីអនុមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| | **ក្រសួងផែនការ** | | |
| ២៣ | លោក **នាយ សត្យា** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ២៤ | លោក **អ៊ុកចាយ បញ្ញាវ៉ា** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតនេះទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ត្រូវបានដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន ០២ នាក់ ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
|---|---|---|---|
| ១ | លោក **ទ៉ាន់ ច័ន្ទផេន** | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ២ | ឯកឧត្តម **អ៊ុក សិទ្ធិជាតិ** | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |

**មាត្រា ២ .-** ត្រូវបានដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន ០៤ នាក់ ក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
|---|---|---|---|
| ១ | លោកស្រី **ធន់ សុគន្ធនារី** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ២ | ឯកឧត្តម **ទុំ សារាវុធ** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៣ | ឯកឧត្តម **លុយ ចណ្ណា** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៤ | ឯកឧត្តម **សៀង សុវណ្ណា** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៤៤ . អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការលុបឈ្មោះមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩//០៨ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.** ~ លុបឈ្មោះលោក **សុខ មុនីរតនា** ប្រធាននាយកដ្ឋានទឹកស្អាត និងអនាម័យ ចេញពីក្របខ័ណ្ឌក្រសួងធនធានទឹក និងឧតុនិយម ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ដោយមូលហេតុមរណភាព ។

**មាត្រា ២.** ~ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ :...៥៨...អនក.ស

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ (6th ASEAN Tourism Investment Forum 2014) សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ (International Conference on Community Development Through Tourism) និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014 នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០១៤

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- សេចក្តីជូនដំណឹងលេខ ៨៥ សជណ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ (6th ASEAN Tourism Investment Forum 2014) សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ (International Conference on Community Development through Tourism) និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014 នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៤ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ថោង ខុន**   រដ្ឋមន្ត្រីក្រសួងទេសចរណ៍   ប្រធាន

| | | |
|---|---|---|
| ២- ឯកឧត្តម **សូ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្តម **ថិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- ឯកឧត្តម **ជា បូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥- ឯកឧត្តម **ង៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៦- ឯកឧត្តម **អ៊ុក សុជាតិ** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧- ឯកឧត្តម **តែ គុយស៊ាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៨- លោកជំទាវ **ប៉ែន មុនីមករា** | អនុរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៩- ឯកឧត្តម **នួន សុមេធ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១០- ឯកឧត្តម **ខិក តារារិទ្ធិ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១១- ឯកឧត្តម **ណូ សម្បូរ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ១២- ឯកឧត្តមឧត្តមសេនីយ៍ឯក **យុន ឈុន្នី** អគ្គស្នងការរងនគរបាលជាតិ | | សមាជិក |
| ១៣- ឯកឧត្តម **ណេប សាមុត** | អគ្គនាយកទេសចរណ៍ និងជាអគ្គលេខាធិការរង គ.អ.ធ.ក. | សមាជិក |
| ១៤- ឯកឧត្តម **គង់ សុលីដា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ | សមាជិក |
| ១៥- លោកជំទាវ **ម៉ក់ វណ្ណស៊ីថា** | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ១៦-ឯកឧត្តម **ឯម យិនទីរៈ** | អគ្គនាយករងគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៨-ឯកឧត្តមឧត្តមសេនីយ៍ឯក **ចាន់ គឹមសេង** ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ | | សមាជិក |
| ១៩- ឧត្តមសេនីយត្រី **ណឹម សុទ្ធិសាល** ស្នងការរង ស្នងការដ្ឋានប្រតិបត្តិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |

គណៈកម្មការនេះមានភារកិច្ចដឹកនាំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ (6th ASEAN Tourism Investment Forum 2014) សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ (International Conference on Community Development through Tourism) និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014 នៅរាជធានីភ្នំពេញចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៤ ឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

**ប្រការ២:** ត្រូវបានបង្កើតអនុគណៈកម្មការចំនួន ០៥ ដើម្បីជាសេនាធិការដល់គណៈកម្មការនេះ។

- **អនុគណៈកម្មការទី១:** អនុគណៈកម្មការឃោសនា ផ្សព្វផ្សាយ និងរៀបចំតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សូ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- | ឯកឧត្តម **ណេប សាមុត** | អគ្គនាយកទេសចរណ៍ | អនុប្រធាន |
| ៣- | ឯកឧត្តម **អាំង សុវណ្ណរ័ត្ន** | អគ្គនាយករងទេសចរណ៍ | អនុប្រធាន |
| ៤- | លោក **ទ្រី ឈឹម** | អគ្គនាយករងទេសចរណ៍ | សមាជិក |
| ៥- | លោក **សូ ទិសុទ្ធី** | ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ៦- | លោក **ឡោ ធូរ៉ា** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ៧- | លោក **ទ័ន មុន្នីវឌ្ឍនៈ** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ៨- | លោក **ហ៊ុល សិលា** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ៩- | លោកស្រី **តឹក សុតី** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ១០- | លោក **យិន ស៊ីផេង** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |

| | | |
|---|---|---|
| ១១- លោក **ប្រាក់ វុទ្ធី** | នាយការិយាល័យនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ១២- លោក **ចាន ប៊ុនចាន** | នាយការិយាល័យនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ១៣- លោក **តាត វិសុទ្ធមុនី** | នាយការិយាល័យនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ១៤- លោក **ពា តាព** | នាយការិយាល័យនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ១៥- លោក **លី វណ្ណៈ** | នាយការិយាល័យនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ១៦- កញ្ញា **ត្រួយ លីនដា** | នាយការិយាល័យនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ១៧- លោក **ឈុន មករា** | ប្រធានផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ គ.ជ.វ.ទ | សមាជិក |

**អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖**

-ធ្វើការឃោសនាផ្សព្វផ្សាយពីព្រឹត្តិការណ៍វេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ (6th ASEAN Tourism Investment Forum 2014) សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ (International Conference on Community Development through Tourism) និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014 ទាំងក្នុង និងក្រៅប្រទេស តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន។

-សហការជាមួយសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិក (PATA) ដើម្បីរៀបចំដំណើរការតាំងពិព័រណ៍ PATA Travel Mart 2014។

-សម្របសម្រួលជាមួយសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិក (PATA) ក្នុងការចុះឈ្មោះ និងបញ្ជាក់ការចូលរួមរបស់គណៈប្រតិភូ អ្នកទិញ (Buyers) អ្នកលក់ (Sellers) និងអ្នកសារព័ត៌មាន (Media)

-ស្វែងរកអ្នកទិញ (Buyers) អ្នកលក់(Sellers) និងអ្នកសារព័ត៌មាន (Media)ដើម្បីចូលរួមពិព័រណ៍ PATA Travel Mart 2014។

-សហការជាមួយអនុគណៈកម្មការរៀបចំពិធីការ ស្នាក់នៅ ហូបចុក ដឹកជញ្ជូន និងហិរញ្ញវត្ថុ ដើម្បីរៀបចំការស្នាក់នៅ ហូបចុក និងដឹកជញ្ជូនសម្រាប់អ្នកទិញ អ្នកលក់ អ្នកសារព័ត៌មាន និងគណៈប្រតិភូនានា។

➢ **អនុគណៈកម្មការទី២: អនុគណៈកម្មការរៀបចំពិធីបើក ពិធីបិទ និងទស្សនីយភាពសិល្បៈ**

| | | |
|---|---|---|
| ១-ឯកឧត្តម **ផាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២-ឯកឧត្តម **អ៊ុក សុជាតិ** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣-ឯកឧត្តម **ឈោប សាមុត** | អគ្គនាយកទេសចរណ៍ | អនុប្រធាន |
| ៤-លោក **សូ វិសុទ្ធី** | ប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ | សមាជិក |
| ៥-លោក **គ្រឿង ឈាង** | ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៦-លោក **ម៉ៅ គេង** | ប្រធាននាយកដ្ឋានទស្សនីយភាពសិល្បៈ | សមាជិក |
| ៧-លោកស្រី **សំ ធីតា** | អនុប្រធាននាយកដ្ឋានសារមន្ទីរ | សមាជិក |
| ៨-លោក **ឈឹម សុធី** | អនុប្រធាននាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បសិប្បកម្ម | សមាជិក |
| ៩-លោក **អ៊ឹង មុន្នី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ១០- លោក **យិន ស៊ីផេង** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ១១- លោកស្រី **តឹក សុភី** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ១១- លោក **ហេង សុខចំរើន** | នាយករងខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១២- លោក **នង មុន្នីកា** | ពិធីការឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៣- លោក **សុខ ស៊ីណារិទ្ធ** | នាយការិយាល័យ នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

-សហការជាមួយសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិក (PATA) មជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាតកោះពេជ្រ និង ក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំពិធីបើក ពិធីបិទ និងទស្សនីយភាពសិល្បៈ សម្រាប់បម្រើដល់វេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014។

➢ **អនុគណៈកម្មការទី៣:** អនុគណៈកម្មការរៀបចំវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ និងកិច្ចប្រជុំពាក់ព័ន្ធនានា

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- | ឯកឧត្តម **ណេប សាមុត** | អគ្គនាយកទេសចរណ៍ | អនុប្រធាន |
| ៣- | ឯកឧត្តម **អាំង សុវណ្ណរ័ត្ន** | អគ្គនាយករងទេសចរណ៍ | អនុប្រធាន |
| ៤- | លោក **ជា កុសល** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជានាយកខុទ្ទកាល័យ | សមាជិក |
| ៥- | លោក **ថុក សុខុម** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន | សមាជិក |
| ៦- | លោក **សុខ សុគុណ** | ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ក្រសួងទេសចរណ៍ | សមាជិក |
| ៧- | លោក **ថែន រតនា** | ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាលក្រសួងទេសចរណ៍ | សមាជិក |
| ៨- | លោក **សូ វិសុទ្ធី** | ប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ | សមាជិក |
| ៩- | លោក **ជុក ជំនោរ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ | សមាជិក |
| ១០- | លោក **គីម សេរីរដ្ឋ** | ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ | សមាជិក |
| ១១- | លោក **ជួន ជ័យសត្យា** | ប្រធានក្រុមអ្នកច្បាប់ក្រសួងទេសចរណ៍ | សមាជិក |
| ១២- | លោក **ឈុន ណាក់** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន | សមាជិក |
| ១៣- | លោក **សយ ផល្លា** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន | សមាជិក |
| ១៤- | លោក **យិន ណាត** | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ | សមាជិក |
| ១៥- | លោកស្រី **ហួត ស៊ីនួន** | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ | សមាជិក |
| ១៦- | លោក **សោម ម៉ុនណាត** | នាយការិយាល័យទំនាក់ទំនងអន្តរជាតិ | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ចខាងដូចក្រោម៖

-ទំនាក់ទំនងជាមួយលេខាធិការដ្ឋានអាស៊ាន ក្រសួង ស្ថាប័ន និងផ្នែកឯកជនពាក់ព័ន្ធដើម្បីរៀបចំកម្មវិធីសមាសភាពគណៈប្រតិភូចូលរួម រៀបចំខ្លឹមសារ និងឯកសារពាក់ព័ន្ធសម្រាប់កិច្ចប្រជុំនានានៃវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិក និងកិច្ចប្រជុំពាក់ព័ន្ធនានា។

-សម្របសម្រួល និងតាមដានអំពីការអញ្ជើញចូលរួមរបស់គណៈប្រតិភូក្នុងវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិក និងកិច្ចប្រជុំពាក់ព័ន្ធនានា។

-រៀបចំសុន្ទរកថា ជំនួយស្មារតី និងឯកសារពាកព័ន្ធសម្រាប់ថ្នាក់ដឹកនាំ។

➢ **អនុគណៈកម្មការទី៤:** អនុគណៈកម្មការរៀបចំពិធីការ ស្នាក់នៅ ហូបចុក ដឹកជញ្ជូន និងហិរញ្ញវត្ថុ

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ជា ប៊ុនរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- | ឯកឧត្តម **ណូ សម្បូរ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣- | ឯកឧត្តម **គង់ សុលីដា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- | លោក **ផ្លុង ធឿន** | អគ្គនាយករង និងជាប្រធាននាយកដ្ឋានរដ្ឋបាល- កិច្ចការទូទៅ | សមាជិក |
| ៥- | លោក **ប្រាក់ ច័ន្ទតារា** | អគ្គនាយករងទេសចរណ៍ | សមាជិក |
| ៦- | លោក **នឹម សុវណ្ណ** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៧- | លោក **សុខ គុយហាប់** | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | សមាជិក |
| ៨- | លោក **គីម សេរីរដ្ឋ** | ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ | សមាជិក |
| ៩- | លោក **ខែន រតនា** | ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល | សមាជិក |
| ១០- | លោក **តាំង សុចិត្រាគ្រីស្ណា** | ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ | សមាជិក |
| ១១- | លោក **ហេង សុដានី** | អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | សមាជិក |
| ១២- | លោក **ម៉ម ខាសនា** | អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | សមាជិក |
| ១៣- | លោក **ហង្ស សណ្តាប់** | អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម:

-រៀបចំទទួលស្វាគមន៍គណៈប្រតិភូ អ្នកទិញ (Buyers) អ្នកលក់ (Sellers) និងអ្នកសារព័ត៌មាន (Media) ដែលមកចូលរួមវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ឆ្នាំ២០១៤ សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014។

-សហការជាមួយគ្រប់អនុគណៈកម្មការ ដើម្បីរៀបចំវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014។

-រៀបចំបញ្ជរស្វាគមន៍ និងច្រកចេញ-ចូលដោយឡែកសម្រាប់គណៈប្រតិភូ អ្នកទិញ ( Buyers) អ្នកលក់ (Sellers) និងអ្នកសារព័ត៌មាន (Media)។

-រៀបចំមន្ត្រីទំនាក់ទំនង (LO) អ្នកស្ម័គ្រចិត្ត និងមគ្គុទ្ទេសក៍ សម្រាប់ទទួលគណៈប្រតិភូអ្នកទិញ ( Buyers) អ្នកលក់ (Sellers) និងអ្នកសារព័ត៌មាន (Media)។

-សម្របសម្រួលបែបបទគយ និងរដ្ឋាករ។

-រៀបចំមធ្យោបាយដឹកជញ្ជូន និងខ្សែទស្សនកិច្ចជូនគណៈប្រតិភូ អ្នកទិញ ( Buyers) អ្នកលក់ (Sellers) និងអ្នកសារព័ត៌មាន (Media)។

-រៀបចំការស្នាក់នៅ ដឹកជញ្ជូន និងហូបចុករបស់គណៈប្រតិភូ សមាគម PATA និងសម្របសម្រួលដល់ការហូបចុក និងដឹកជញ្ជូន របស់អ្នកទិញ អ្នកលក់ និងសារព័ត៌មាន។

-គ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុ ចំណូល ចំណាយ គ្រប់សកម្មភាពនៃដំណើរការរៀបចំវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014។

-ទំនាក់ទំនងជាមួយផ្នែកឯកជន និងដៃគូរពាក់ព័ន្ធនានា ដើម្បីឧបត្ថម្ភអាហារថ្ងៃត្រង់ ពេលល្ងាច សម្រាប់គណៈប្រតិភូ អ្នកទិញ ( Buyers) អ្នកលក់ (Sellers) និងអ្នកសារព័ត៌មាន (Media)។

-បូកសរុបអំពីចំណូល-ចំណាយនៃការរៀបចំព្រឹត្តិការណ៍នេះ។

➢ **អនុគណៈកម្មការទី៥:** អនុគណៈកម្មការការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងសង្គ្រោះបន្ទាន់

| | | | |
|---|---|---|---|
| ១- | ឯកឧត្តមឧត្តមសេនីយឯក **យុន ឈុន្នី** | អគ្គស្នងការរងនគរបាលជាតិ | ប្រធាន |
| ២- | លោកជំទាវ **ម៉ក់ វណ្ណស៊ីថា** | អភិបាលរងរាជធានីភ្នំពេញ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣- | ឯកឧត្តមឧត្តមសេនីយ៍ឯក **ចាន់ គីមសេង** | ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ | អនុប្រធាន |
| ៤- | ឧត្តមសេនីយត្រី **ណើម សុទិសាល** | ស្នងការរង ស្នងការដ្ឋានប្រតិបត្តិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៥- | លោក **ប្រាក់ ចំនួតារា** | អគ្គនាយករងទេសចរណ៍ | សមាជិក |
| ៦- | លោកនិន **សុទ្ធីវង្ស** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៧- | លោក **សាន់ សារី** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ ក្រសួងសុខាភិបាល | សមាជិក |
| ៨- | លោក **ចិន សាម៉ន** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ | សមាជិក |
| ៩- | លោក **តាំង សុចិត្រាត្រីស្នា** | ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ | សមាជិក |

**អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម:**

-រៀបចំការពារសន្តិសុខ សុវត្ថិភាព របៀបរបប សណ្តាប់ធ្នាប់សង្គម និងចរាចរ ឲ្យធានាសុវត្ថិភាពគ្រប់គ្រាន់មុន-ក្រោយ និងក្នុងពេលប្រារព្ធពិធី និងតាមដងផ្លូវឆ្លងកាត់

-ទំនាក់ទំនង និងសហការជិតស្និទជាមួយអាជ្ញាធរសមត្ថកិច្ចនៅអាកាសយានដ្ឋានអន្តរជាតិ និងនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលដល់គណៈប្រតិភូ និងភ្ញៀវអន្តរជាតិដែលអញ្ជើញចូលរួម

-រៀបចំក្បួននាំមុខ និងការពារសន្តិសុខ សុវត្ថិភាពជូនគណៈប្រតិភូ

-ត្រៀមលក្ខណៈ និងមធ្យោបាយគ្រប់គ្រាន់សម្រាប់សង្គ្រោះបន្ទាន់ក្នុងករណីមានបាតុភាពជាយថាហេតុ (រថយន្ត និងគ្រូពេទ្យ សម្រាប់ជួយបំរើសុខមាលភាពគណៈប្រតិភូ)។

**ប្រការ ៣:** ត្រូវបានបង្កើត **លេខាធិការដ្ឋានមួយ** ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | លោក **ផ្លុង ធឿន** | អគ្គនាយករង និងជាប្រធានន.រដ្ឋបាល និងកិច្ចការទូទៅ | ប្រធាន |
| ២- | លោក **ជា កុសល** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជានាយកខុទ្ទកាល័យ | អនុប្រធាន |
| ៣- | លោក **នឹម សុវណ្ណ** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- | លោក **ឡូន សេដា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ៥- | លោកស្រី **ឯម ច័ន្ទសារ៉ាវត្ត** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ៦- | លោកស្រី **គឹក សុគី** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ៧- | លោក **ហេង សុខចំរើន** | នាយករងខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ៨- | លោកស្រី **គឹម សុវណ្ណា** | អនុប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ | សមាជិក |
| ៩- | លោក **នង មុន្នីកា** | ពិធីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១០ | លោក **ឈុន មករា** | ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ គ.ជ.វ.ទ | សមាជិក |
| ១១- | លោកស្រី **សារិន កញ្ញនា** | នាយការិយាល័យរដ្ឋបាល-របៀប | សមាជិក |
| ១២- | លោក **ម៉ែន សុវណ្ណា** | នាយការិយាល័យសរុប | សមាជិក |
| ១៣- | លោក **សៅរី ចំនួតពិសិដ្ឋ** | មន្ត្រីការិយាល័យពិធីការ | សមាជិក |

**លេខាធិការដ្ឋាននេះ មានភារកិច្ចដូចខាងក្រោម:**

-ជាជំនួយការឲ្យគណៈកម្មការក្នុងការងារទំនាក់ទំនង និងសម្របសម្រួលជាមួយគ្រប់អនុគណៈកម្មការ ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

-រៀបចំគម្រោងកម្មវិធីការងាររបស់គណៈកម្មការអន្តរក្រសួង។

-ស្នើសុំការអនុញ្ញាតចូលទស្សនារមណីយដ្ឋានទេសចរណ៍ និងប្រាសាទនានា សម្រាប់គណៈប្រតិភូ។

-រៀបចំលិខិតអញ្ជើញ និងតាមដានបញ្ជាក់ការចូលរួមរបស់គណៈប្រតិភូ និងភ្ញៀវនានា។

-រៀបចំបោះពុម្ពលិខិតអញ្ជើញសម្រាប់ពិធីបើក និងពិធីបិទ។
-តម្លើងកម្មវិធីបើក កម្មវិធីបិទ កម្មវិធីជប់លៀងស្វាគមន៍គណៈប្រតិភូ VIPs, Buyers, Sellers និង Media។
-រៀបចំ និងផ្តល់ស្លាកពាក់ដល់គណៈប្រតិភូ VIPs, Buyers, Sellers និង Media។
-រៀបចំប័ណ្ណរថយន្តសម្រាប់ភ្ញៀវចេញ-ចូល។
-រៀបចំវត្ថុអនុស្សាវរីយ៍សម្រាប់ជូនគណៈប្រតិភូ។
-រៀបចំកិច្ចប្រជុំបច្ចេកទេសនានាសម្រាប់គណៈកម្មការ។
-តាមដាន និងត្រួតពិនិត្យរាល់សកម្មភាពការងាររបស់អនុគណៈកម្មការនីមួយៗ និងរាយការណ៍ជាប្រចាំជូនប្រធានគណៈកម្មការអំពីដំណើរការរៀបចំវេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014។
-បូកសរុប និងរាយការណ៍ពីលទ្ធផលនៃការរៀបចំព្រឹត្តិការណ៍ខាងលើ។

**ប្រការ ៤:** អនុគណៈកម្មការនីមួយៗអាចស្នើសុំជ្រើសរើសសមាជិកបន្ថែមតាមការចាំបាច់ដោយមានការយល់ព្រមពីប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ ៥:** គណៈកម្មការអន្តរក្រសួងមានសិទ្ធិស្វែងរកដៃគូផ្នែកឯកជន ដើម្បីជួយទ្រទ្រង់ដល់ព្រឹត្តិការណ៍វេទិកាវិនិយោគទេសចរណ៍អាស៊ានលើកទី៦ ឆ្នាំ២០១៤ សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍សហគមន៍តាមរយៈវិស័យទេសចរណ៍ និងការតាំងពិព័រណ៍ទេសចរណ៍ PATA Travel Mart 2014 ដែលមានសមាសភាពចូលរួមពីផ្នែកឯកជន និង ដៃគូអភិវឌ្ឍន៍។

**ប្រការ៦:** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍។
-អនុប្រធាន សមាជិកគណៈកម្មការអន្តរក្រសួង និងប្រធាន អនុប្រធានសមាជិកអនុគណៈកម្មការនីមួយៗ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង ។

**ប្រការ ៧:** គណៈកម្មការនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច។

**ប្រការ ៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ១ ប្រការ២ ប្រការ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៤

**ចម្លងជូន៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ដូចប្រការ ៨*
- *ឯកសារ-កាលប្បវត្តិ*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៥៩...សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្ដម **ចាន់ សុខុឌ្ឍ** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២- ឯកឧត្ដម **ឃុត ចាន់ដារ៉ា** | តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- ឯកឧត្ដម **សៅ សុភាព** | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៤- លោក **ម៉ិន បុណ្ណារិទ្ធ** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោក **ហ៊ាង ខុន្ថា** | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- លោក **ប្រាក់ សំអឿន** | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៧- លោក **អ៊ុន អ៉ាល់ឡឺរ៍** | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨- លោក **សៅ រ៉ាវី** | តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក។ |

**ប្រការ២.-**

លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ចនេះ ត្រូវបំពេញភារកិច្ចដូចមានចែងក្នុងអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច។

**ប្រការ៣.-**

សេចក្ដីសម្រេចលេខ ២៧ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ ស្ដីពីការតែងតាំងសមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១១ សហវ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញសេចក្តីសម្រេចលេខ ៤៦ សសរ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស
- យោងលិខិតលេខ ២០៩០ មស.រប ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ ៨១០៣ សហវ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងលិខិតលេខ ១៩០៨ សជណ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ១៨៣/២០១៣ សជណ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងការពារជាតិ
- យោងលិខិតលេខ ២៩៩ ស.អ.យ. ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងប្រកាសលេខ ២៣៨៦ មស.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការទទួលស្គាល់សមាសភាពក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស
- យោងតាមការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានចាត់តាំងសមាសភាពក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម | **សុខ សារាវុឌ្ឍ** | ប្រធាន |
| ២. ឯកឧត្តម | **ផាន់ ផល្លា** | អនុប្រធាន |
| ៣. ឯកឧត្តម | **ហ៊ីង សុវណ្ណ** | សមាជិក |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

| | | |
|---|---|---|
| ៤. ឯកឧត្តម | **ចាន់ សុធី** | សមាជិក |
| ៥. ឯកឧត្តម | **ទេព្យ ម៉ិនឥន្ទ្រាទុច** | សមាជិក |
| ៦. ឯកឧត្តម | **កែវ ចេនចន្ថ្សាន់** | សមាជិក |
| ៧. លោក | **ហាវ រតនៈ** | សមាជិក |
| ៨. លោក | **យ៉េត ទីណែល** | សមាជិកអចិន្ត្រៃយ៍ |
| ៩. លោក | **ម៉ិត សទ្ធារ** | លេខាធិការ |

**ប្រការ២.-**

ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស មានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង និងសម្របសម្រួលជាមួយគ្រប់អង្គភាព នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តការងារដែលជាភារកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកក្នុងការសម្រេចបាននូវភារកិច្ចរបស់ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្សរបស់រាជរដ្ឋាភិបាល
- សិក្សាប្រព័ន្ធបៀវត្សរបស់រាជរដ្ឋាភិបាលជាលក្ខណៈកញ្ចប់ ដោយគ្របដណ្តប់ទាំងមន្ត្រីរាជការថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ, នគរបាលជាតិ, យោធា, និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ
- លើកសំណើអំពីការកែទម្រង់ប្រព័ន្ធបៀវត្សជាលក្ខណៈកញ្ចប់ ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រ សម្រាប់ការដាក់ឲ្យអនុវត្តផែនការកែទម្រង់ប្រព័ន្ធបៀវត្សរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ២០១៤-២០១៨ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដើម្បីគោរពជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

សមាសភាពនៃក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ក្នុងករណីដែលប្រធានអវត្តមាន។

ក្រុមការងារ ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តការងារ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យបានជាប់ជាប្រចាំ។

**ប្រការ៤.-**

ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមការងារដូចបានកំណត់ក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ មីនា ឆ្នាំ២០១៤

ពន្លឺ

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាមីខ្លួនដូចប្រការ ១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ